**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

CAMBODIA
Kingdom of Wonder

**ក្រសួងទេសចរណ៍**

**លេខ** ១៣៧ ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី ០៣ ខែ កក្កដា ឆ្នាំ២០១៥

# ប្រកាស

## ស្តីពីការធ្វើប្រតិភូកម្ម នៃការចារទេសចរណ៍ជូនដល់ខណ្ឌគោលដៅ នៃសាលារាជធានីភ្នំពេញ

### រដ្ឋមន្ត្រីក្រសួងទេសចរណ៍

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៩១៣/៩០៤ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១២១៣/១៣៩៣ ចុះថ្ងៃទី ២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦/១៥ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងទេសចរណ៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៩/០០៧ ចុះថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីទេសចរណ៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ៣៤ អនក្រ-បក ចុះថ្ងៃទី ០៥ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ ៦៨ អនក្រ-បក ចុះថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ២០១៣ ស្តីពីការផ្តល់សេវារដ្ឋបាល នៅរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញសេចក្តីសម្រេចលេខ ៤៧ សសរ ចុះថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០០៣ របស់រាជរដ្ឋាភិបាល ស្តីពីរចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងស្រុកសៀមរាប ខេត្តសៀមរាប និងស្រុកបាត់ដំបង ខេត្តបាត់ដំបង
- បានឃើញសេចក្តីសម្រេចលេខ ១២ សសរ ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៨ របស់រាជរដ្ឋាភិបាល ស្តីពីការបង្កើតការិយាល័យច្រកចេញ-ចូលតែមួយ និងការិយាល័យប្រជាពលរដ្ឋ
- យោងប្រកាសលេខ ០២៩ ប្រក ចុះថ្ងៃទី០២ ខែឧសភា ឆ្នាំ២០០១ របស់ក្រសួងទេសចរណ៍ ស្តីពីការផ្តល់អាជ្ញាប័ណ្ណទេសចរណ៍ជូនភ្នាក់ងារ និងក្រុមហ៊ុនប្រកបអាជីវកម្មកីឡាទេសចរណ៍ និងកំសាន្ត
- យោងប្រកាសលេខ ០៦៣ ប្រក ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៧ របស់ក្រសួងទេសចរណ៍ ស្តីពីការផ្តល់អាជ្ញាប័ណ្ណទេសចរណ៍ដល់អាជីវកម្ម សណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍
- យោងប្រកាសលេខ ០៦៤ប្រក ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៧ របស់ក្រសួងទេសចរណ៍ ស្តីពីការផ្តល់អាជ្ញាប័ណ្ណទេសចរណ៍ដល់មធ្យោបាយធ្វើអាជីវកម្មដឹកជញ្ជូនទេសចរ ធ្វើដំណើរទស្សនាកំសាន្តតាមផ្លូវគោក
- យោងប្រកាសលេខ ០៧៤ ប្រក ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០០៨ របស់ក្រសួងទេសចរណ៍ ស្តីពីការផ្តល់អាជ្ញាប័ណ្ណដល់អាជីវកម្មខារ៉ាអូខេ

- យោងប្រកាសលេខ ០៧៥ ប្រក ចុះថ្ងៃទី ១៣ ខែមិថុនា ឆ្នាំ២០០៨ របស់ក្រសួងទេសចរណ៍ ស្តីពីការផ្តល់អាជ្ញាប័ណ្ណទេសចរណ៍ដល់អាជីវកម្ម សេវាកម្មម៉ាស្សាសុខភាព.ស្ប៉ា
- យោងប្រកាសលេខ ០៧៦ ប្រក ចុះថ្ងៃទី ១៣ ខែមិថុនា ឆ្នាំ២០០៨ របស់ក្រសួងទេសចរណ៍ ស្តីពីការផ្តល់អាជ្ញាប័ណ្ណទេសចរណ៍ អាជីវកម្ម ភោជនីយដ្ឋាន និងអាហារដ្ឋាន
- យោងប្រកាសលេខ ៩២៨ប្រក ចុះថ្ងៃទី ១២ ខែមីនា ឆ្នាំ២០០៩ របស់ក្រសួងមហាផ្ទៃ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃការិយាល័យច្រកចេញចូលតែមួយនៅក្រុង ស្រុក ខណ្ឌគោលដៅ
- យោងសេចក្តីសម្រេចលេខ ៤៣៧៣ សសរ ចុះថ្ងៃទី ០៨ ខែមេសា ឆ្នាំ២០១៥ របស់ក្រសួងមហាផ្ទៃ ស្តីពីការកំណត់ខណ្ឌគោលដៅសម្រាប់អនុវត្តការិយាល័យច្រកចេញចូលតែមួយ និងការិយាល័យប្រជាពលរដ្ឋ
- យោងសេចក្តីសម្រេចលេខ ២៣០៧ សសរ ចុះថ្ងៃទី ១៧ ខែមិថុនា ឆ្នាំ២០១៥ របស់ក្រសួងមហាផ្ទៃ ស្តីពីការផ្ទេរការិយាល័យច្រកចេញចូលតែមួយ និងការិយាល័យប្រជាពលរដ្ឋ ពីរចនាសម្ព័ន្ធសាលាខណ្ឌមានជ័យ ទៅរចនាសម្ព័ន្ធសាលាខណ្ឌច្បារអំពៅ
- យោងលិខិតលេខ ៨៤៩ លស ចុះថ្ងៃទី ១១ ខែឧសភា ឆ្នាំ២០១៥ របស់ក្រសួងមហាផ្ទៃ។

## សម្រេច

**ប្រការ ១.-**

ធ្វើប្រតិភូកម្មជូនដល់ខណ្ឌគោលដៅ នៃការិយាល័យច្រកចេញចូលតែមួយនៅរាជធានីភ្នំពេញ នូវសេវាកម្មទេសចរណ៍មួយចំនួនដូចខាងក្រោម ៖

| | |
|---|---|
| - **សេវាស្នាក់នៅ** : | ផ្ទះភ្ញៀវ ០៨ បន្ទប់ចុះក្រោម ផ្ទះមានបន្ទប់ជួលធម្មតា និងបន្ទប់ជួល ដែលពុំមានចែងនៅក្នុងប្រកាស ស្តីពីការផ្តល់អាជ្ញាប័ណ្ណទេសចរណ៍ដល់សេវាកម្មស្នាក់នៅទេសចរណ៍។ |
| - **សេវាម្ហូបអាហារ** : | អាហារដ្ឋាន និងភោជនីយដ្ឋានទេសចរណ៍ខ្នាតតូច ឬ អាហារដ្ឋាន និងភោជនីយដ្ឋានក្នុងខណ្ឌចំណុះក្រោម ៥០នាក់ តូបលក់អាហារ ហាងលក់គុយទាវ-កាហ្វេ និងហាងលក់សាច់អាំងធម្មតា បម្រើភ្ញៀវទេសចរ។ |
| - **សេវាដឹកជញ្ជូនទេសចរណ៍** : | រថយន្តដឹកទេសចរណ៍ចំណុះ ០៥ កៅអី។ |
| - **សេវាម៉ាស្សា** : | ដើម្បីសុខភាពចាប់ពី ០៥គ្រែ ឬ ០៥ កៅអីចុះក្រោម |
| - **កីឡាស្នូកឃែរ** : | ចាប់ពី ០៥ តុ ចុះក្រោម។ |
| - **ខារ៉ាអូខេ** : | ចាប់ពី ០៥ បន្ទប់ ចុះក្រោម និងខារ៉ាអូខេដែលមិនមានចែងក្នុងប្រកាស ស្តីពីការផ្តល់អាជ្ញាប័ណ្ណទេសចរណ៍ដល់អាជីវកម្មខារ៉ាអូខេ។ |

**ប្រការ ២.-**

ក្រសួងទេសចរណ៍ បានចេញនូវសេចក្តីណែនាំលេខ ០០៨ សណន ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១០ ស្តីពីការអនុវត្តន៍ប្រកាសប្រតិភូកម្មនៃការងារទេសចរណ៍ជូនដល់ក្រុង ស្រុកខណ្ឌ គោលដៅ ដែលបានចែងអំពីនីតិវិធីអនុវត្ត និងគំរូបែបបទផ្សេងៗ ពាក់ព័ន្ធដល់ការចេញអាជ្ញាប័ណ្ណទេសចរណ៍ សម្រាប់មន្ត្រីជំនាញការិយាល័យទេសចរណ៍ក្រុងស្រុក ខណ្ឌ គោលដៅ និងមន្ត្រីការិយាល័យច្រកចេញចូលតែមួយ ដើម្បីងាយស្រួលក្នុងកិច្ចសហការអនុវត្តការងារនេះឱ្យបានល្អ។

**ប្រការ ៣.-**

សាលាខណ្ឌគោលដៅ នៃការិយាល័យច្រកចេញចូលតែមួយ ក្រោយពីចេញអាជ្ញាប័ណ្ណទេសចរណ៍ ជូនដល់បណ្តាអាជីវកម្ម ដូចក្នុង ប្រការ១ ត្រូវថតចម្លងអាជ្ញាប័ណ្ណទេសចរណ៍ជូនការិយាល័យទេសចរណ៍ខណ្ឌ និងផ្តល់នូវរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំជូនមន្ទីរទេសចរណ៍រាជធានីភ្នំពេញ និងសាលារាជធានី ភ្នំពេញ ដើម្បីមន្ទីរទេសចរណ៍ សរុបរបាយការណ៍ជូនក្រសួង។

**ប្រការ ៤.-**

ប្រកាសនេះមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រដ្ឋមន្ត្រី

**ថោង ខុន**

**ចម្លងជូនៈ**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- សាលារាជធានីភ្នំពេញ

"ដើម្បីជូនជ្រាប"

- មន្ទីរទេសចរណ៍រាជធានីភ្នំពេញ
- សាលាខណ្ឌគោលដៅ
- ការិយាល័យទេសចរណ៍ខណ្ឌគោលដៅ

"ដើម្បីអនុវត្ត"

- ឯកសារ-កាលប្បវត្តិ